# របាយការណ៍ប្រជុំប្រចាំឆ្នាំ ២០០៨ របស់អង្គការសេដាក និសដៅឆ្នាំ ២០០៩ ~ ២០១១

កាលបរិច្ឆេទៈ ថ្ងៃទី ៣០-៣១ ខែធ្នូ ឆ្នាំ ២០០៨

ទីកន្លែងៈ សាលប្រជុំមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)

អ្នកចូលរួមៈ ២៣៩ នាក់

អ្នកសម្របសម្រួលៈ លោក គាត់ សុខ, លោក ឃឹម សុផាណ្ណា, លោក ប្រាក់ សេរីវឌ្ឍន៍, អ្នកស្រី តុង ចាន់ធាង កញ្ញា សយ សុភ័ក្រ្តា និងកញ្ញា លុយ ធារី

---

**ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៨ៈ (ពេលព្រឹក) អ្នកសម្របសម្រួលៈ លោក គាត់ សុខ**

នៅម៉ោង ៨ៈ00 គត់ កម្មវិធីបានចាប់ដំណើរការដោយ លោក គាត់ សុខ បានធ្វើការណែនាំពីកម្មវិធីប្រជុំសម្រាប់រយៈពេលពីរថ្ងៃនេះ បន្ទាប់មកគឺជាការអញ្ជើញគណៈអធិបតីចូលកៅអីកិត្តិយស និងការគោរពភ្លេងជាតិ។ បន្ទាប់មក គណៈអធិបតីបានធ្វើការចាប់អារម្មណ៍ទាក់ទងនឹងការប្រជុំនេះ។ លោក ឃឹម សុផាណ្ណា បានមានប្រសាសន៍ថា ពេលបច្ចុប្បន្ននេះការប្រជុំពេញអង្គយើងធ្វើត្រឹមតែ ២-៣ ដង ក្នុងមួយឆ្នាំ យើងមិនងាយបានជួបជុំគ្នាទេ ដោយសារបុគ្គលិកយើងច្រើន ពីមុនយើងជួបជុំញឹកញាប់។ ដោយឡែកឆ្នាំនេះ យើងក៏បានជួបជុំជាក្រុមចំនួន ៥ លើកនៅ Picnic និងការរៀបចំវេទិកាគ្រូបង្រៀន។ ជាសំណូមពរ លោកបានឱ្យបុគ្គលិកយើងត្រូវចងចាំអំពីចក្ខុវិស័យ និងគុណតម្លៃរបស់ សេដាក និងត្រូវបន្តការសហការឱ្យបានកាន់តែប្រសើរជាមុន។

ចំពោះលោក អ៊ុង តារារ័ត្នមុនី ក៏បានចាប់អារម្មណ៍អំពីការប្រជុំពេញអង្គរបស់ សេដាក ដែលធ្វើនៅឆ្នាំ ២០០៧ ទាក់ទងនឹងយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល បើប្រៀបធៀបមក សេដាក យើងបច្ចុប្បន្នគឺបានបំពេញគ្រប់ចតុកោណនោះ។ យើងបានរក្សាទុកចំណេះដឹង បញ្ជ្រាបពីសហគ្រាសខ្នាតតូច បង្កើតវិទ្យាស្ថានអភិវឌ្ឍន៍ សេដាក និងបានបោះជំហានទៅមុខ ប៉ុន្តែក្នុងវិស័យច្បាប់ពុំដឹងថាយើងបានគិតយ៉ាងណានោះទេ។ លោកនឹងមានចំណាប់អារម្មណ៍បន្ថែមទៀតនៅពេលល្ងាច។

លោកស្រី ពាន សុខា បានមានចំណាប់អារម្មណ៍ថា ឆ្នាំ ២០០៨ នេះ បុគ្គលិកមានចំនួនច្រើន ទំហំការងារក៏មានច្រើន ហើយយើងតែងតែគិត និងកែលម្អជាប់ជានិច្ច។

បណ្ឌិត យ៉ង សាំងកុមារ មានប្រសាសន៍ថាការប្រជុំនេះមានលក្ខណៈពិសេស ប៉ុន្តែយើងមិនអាចហៅ CFA ចូលរួមទាំងអស់បានទេ ដោយសារមានការចំណាយច្រើន។ លោកក៏បានលើកឡើងពីប្រវត្តិនៃការកកើត សេដាក ដែលដំបូងយើងធ្វើកសិកម្មជាលក្ខណៈគ្រួសារ ហើយបច្ចុប្បន្នយើងបានបន្ថែមការងារសន្សំប្រាក់។ លោកបានចាប់អារម្មណ៍នូវចំណុចលេចធ្លោមួយចំនួនដែលមាននៅឆ្នាំ ២០០៨ ដូចជាៈ

- ចលនាសន្សំប្រាក់ ដែលមានការកើនឡើង ទាំងចំនួនភូមិ ចំនួនប្រាក់សន្សំ ចំនួនសមាជិកចូលរួម។ល។

- ការផ្តល់ឱកាសឱ្យយុវជនជនបទបានចូលរួមវគ្គបណ្តុះបណ្តាលមានចំនួន ២៨៧ នាក់ ( ស្រ្តី ៣0%)
- ក្រុម CFA ចំនួន ៦២ បានជម្រុញឱ្យចូលជាបុគ្គលិក សេដាក មានចំនួន ៦ នាក់
- ការជម្រុញ SRI មានការយកចិត្តទុកដាក់ច្រើន ជាពិសេសបញ្ហាបការទុកដាក់ពូជ ចងក្រងក្រុមស្រូវសិរីរាង្គ ៨000 គ្រួសារ និងគ្រោងទិញស្រូវ ៤000 តោន ប៉ុន្តែយើងទិញមិនបានគ្រប់ចំនួនដោយសារវិបត្តិហិរញ្ញវត្ថុ
- បានវិនិយោគលើកធ្វើជំនួញច្រើន ដំបូងយើងមានការឆ្លង តែទីបំផុតយើងបានរៀនសូត្រពីបទពិសោធន៍

លោកបានបន្តថា ហេតុអ្វីបានជាវិវត្តន៍ដល់នេះ? គឺដោយសារៈ

១. ព្យាយាមពង្រឹង ពង្រីក និងជម្រុញនូវការពិភាក្សាគ្នា បុគ្គលិកយើងមានភាពចាស់ទុំច្រើនក្នុងការជជែកពិភាក្សាគ្នា
២. វប្បធម៌ពិសោធន៍សាកល្បង ដោយលោកយល់ថាមនុស្សដែលជោគជ័យជាមនុស្សដែលធ្វើការងារមានកំហុសច្រើនបំផុត
៣. វប្បធម៌នៃការសន្សំមានការកើនឡើង ដែលយើងមានទុន ៣៥ ម៉ឺនដុល្លា ហើយនៅឆ្នាំនេះយើងចំណេញការប្រាក់ជាង ៣ ម៉ឺនដុល្លា ជាមួយគ្នានេះបុគ្គលិកយើងក៏បានសន្សំក្នុងការវិនិយោគនៅ CESDE ដែលមានការប្រាក់ ៥%/ឆ្នាំ ហើយយើងនឹងគ្រោងបង្កើនដល់ ១0% នៅឆ្នាំ ២00៩។
៤. យើងបានអាន សរសេរសៀវភៅខ្មែរច្រើន ជាមួយគ្នានេះលោកប្រធានក៏បានលើកទឹកចិត្តដល់បុគ្គលិកចំនួន ៤ រូប ដោយបានផ្តល់នូវវត្ថុអនុស្សាវរីយ៍ ក.ម៉ុក ចិន្តា ក.ឈឹម សុគន្ធារី លោក អ៊ី ណារ៉ុន និងលោកស៊ុន ហ៊ៃល។

ចំពោះគំនិតសម្រាប់ ៣ ឆ្នាំខាងមុខ យើងគ្រោងពង្រីកផ្សារ សេដាក គ្រប់ខេត្ត-ក្រុង ធ្វើជំនួញស្រូវសហគមន៍ ឃើញថាមានស្ថានភាពល្អ ដោយប្រើប្រាស់ថវិកាអំណោយ និងប្រាក់កម្ចី ដែលយើងគ្រោងខ្ចី ៣-៤ លានដុល្លាទៀត។

ចំពោះចំណាប់អារម្មណ៍នូវការងារលេចធ្លោឆ្នាំ ២00៨ សម្រាប់ សេដាក និងសម្រាប់ផ្ទាល់ខ្លួន អ្នកចូលរួមទាំងអស់បានសរសេរដាក់ក្នុងក្រដាសតូចៗ រួចបិទនៅនឹងជញ្ជាំង។ អ្នកចូលរួម បានធ្វើការសង្ខេបនូវចំណុចលេចធ្លោសម្រាប់ សេដាក ក្នុងឆ្នាំ ២00៨ មានដូចជាៈ ការងារសន្សំ ការបណ្តុះបណ្តាលយុវជនជនបទ ប្រព័ន្ធផ្សព្វផ្សាយ Team Spirit, ការទទួលស្គាល់ពីស្ថាប័នរដ្ឋាភិបាល ផ្នែកទាំង ៣ ស្វ័យតភាព វិទ្យុសម្លេងកសិករ ការសហការបានល្អ អភិវឌ្ឍន៍សង្គម បក្សពួកនិយម ក្រុមគោលដៅច្រើន គំនិតថ្មីក្នុងវិស័យកសិកម្ម ការទុកដាក់ពូជ មានជំនាញចម្រុះ តូបសហគមន៍ អភិវឌ្ឍន៍សហគមន៍ មានការអនុវត្តន៍ជាក់ស្តែងលើបច្ចេកទេសកសិកម្ម អ្នកដឹកនាំសំខាន់ៗចុះជាប់តាមមូលដ្ឋាន ជំនួញស្រូវសរីរាង្គ។ល។ ( លម្អិតមាននៅក្នុងសន្លឹកកាតតូចៗ)

ចំពោះភាពលេចធ្លោផ្ទាល់ខ្លួនសម្រាប់ឆ្នាំ ២00៨ មានដូចជាការដាក់វិន័យខ្លួនឯងក្នុងការអាន សង្កេត និងការបើកបេះដូងទទួលយកគំនិត បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម តរិយាបថផ្ទាល់ខ្លួន ភាពចាស់ទុំក្នុងការងារ

អត់ធ្មត់ សប្បាយរីករាយ ចេះធ្វើឆ្លាត សមត្ថភាពក្នុងការសម្របសម្រួល ការងារគ្រប់គ្រង របាយការណ៍ទាន់ពេល ការគិតបានច្រើន ការសន្សំកើននៅ CCC និងក្រុមខាងក្រៅ គ្មានក្រុមរលាយ ធ្វើការអស់ពីចិត្ត ជាជនគំរូសម្រាប់កសិករ មានអ្នកជឿច្រើន គោលការណ៍ សេដាក ខុសគេដោយសារគំនិត និងឆន្ទៈ រៀនសូត្រពីបុគ្គលិក ទទួលខុសត្រូវ គំនិតផ្តួចផ្តើមត្រូវធ្វើដោយខ្លួនឯង ការដាក់ចិត្តដាក់កាយ ។ល។ (លម្អិតមាននៅក្នុងសន្លឹកកាតតូចៗ)

**សំរាកអាហារសម្រន់ ( ១៥ នាទី):**

☞ លោកតាត់សុខបានបន្តសម្របសម្រួលកម្មវិធីចំណាប់អារម្មណ៍របស់តំណាងកសិករ

**កសិករ រស់ ម៉ៅ (តាកែវ):** មុនចូលសហការជាមួយ សេដាក ជីវិតដូចចកអណ្តែតទឹក ក្រោយពីបានសហការជាមួយ សេដាក នៅឆ្នាំ ២០០១ មក មានហូបគ្រប់គ្រាន់ និងសល់បានលក់ មានបទពិសោធន៍ អនុវត្តបានជោគជ័យ ដីតូចដាំបានផលច្រើន ការចិញ្ចឹមសត្វ សួនដំណាំ ជីកំប៉ុស្ត និងទទួលបានជោគជ័យស្ទើរមិនជឿខ្លួនឯង។

**កសិករ អ៊ួន សុផល (កំពត):** សប្បាយចិត្តដោយបានសហការជាមួយ សេដាក ដោយ សេដាក ធ្វើការជាមួយកសិករចុះផ្ទាល់ តាមដានជាប់ជានិច្ច ផ្តល់យោបល់ពីបច្ចេកទេស បណ្តុះបណ្តាលកសិករវ័យក្មេងមានការលូតលាស់ ៧៥% ទទួលជោគជ័យ និងអនុវត្តតាម សេដាក។ ការនិយាយស្តីក្នុងចំណោមសាធារណៈមិនខ្លាច បានផ្តល់បច្ចេកទេសកសិកម្មល្អៗ បណ្តុះបណ្តាលឱ្យចេះដឹកនាំបន្ត មានការជួបជុំគ្នាផ្លាស់ប្តូរបច្ចេកទេសល្អៗ ឆ្លុះបញ្ចាំងធ្វើឱ្យអាជ្ញាធរមូលដ្ឋានមានការអនុគ្រោះដោយសារ សេដាក ធ្វើការចំគោលដៅ។ ចំពោះខ្លួនឯងខិតខំព្យាយាមសាកល្បងជានិច្ច រៀនសូត្រជានិច្ច ទទួលនូវការរិះគន់ជានិច្ច ថ្នៃប្រឌិតជានិច្ច ហើយអ្វីដែលរីកធំជាងគេគឺសន្សំប្រាក់ និង ប.រ.ស។

**កសិករ ហ៊ិន សារឿន (ព្រៃវែង):** ជាកសិកររស់នៅជាមួយមេរោគ HIV បានសហការជាមួយ សេដាក បង្កើតជាក្រុមសន្សំដែលមានសមាជិក ១៦ នាក់ ចេះអនុវត្តការចិញ្ចឹមសត្វ ដាំបន្លែ ចិញ្ចឹមត្រី ដាំស្រូវ និងបានរៀបចំបុណ្យអង្គ្រេសបញ្ចុំយបានជាង ២ លានរៀល ក្រុមសន្សំមានប្រាក់ ១៩ លានរៀល នៅបាភ្នំ។

**លោក ស អ៊ូច:** ដោយមានងារជាសេដ្ឋីស្រុកស្រែ លោកមានការផ្លាស់ប្តូរ និងរីកចំរើនច្រើនដូចជា មានគំនិតនិងចេះគិតច្រើនជាងមុន, មើលឃើញចក្ខុវិស័យទៅមុខច្បាស់លាស់ (ចង់ក្លាយជាសេដ្ឋីស្រុកស្រែ), មើលឃើញតែលុយ និងការចំណេញ ជាក់ស្តែងការសន្សំរបស់គាត់ក្នុងមួយខែបាន ១០ លានរៀល។ ចំពោះសហគមន៍វិញប្រជាជននៅក្នុងភូមិរបស់គាត់មានការងារធ្វើច្រើន ចេះវិភាគ ចេះថ្លឹងថ្លែងមុនធ្វើអ្វីមួយ មានកន្លែង និងទ្រុងចិញ្ចឹមមាន់ច្រើន ហើយលុយសន្សំបានហូរទៅដល់ភូមិក្បែរខាងថែមទៀត។

**កសិករ សេង ស្រីឡា (ព្រៃវែង):** បង្កើតក្រុមសន្សំដែលមុនដំបូងមានគ្នា ៨ នាក់ ឥឡូវមាន ១៥០ នាក់ មានប្រាក់សន្សំ ២៧ លានរៀល ដែលមិនស្មានថាបង្កើតបានដូច្នេះ មានភាពក្លាហាន មានជីវភាពធូរធារ។

**កសិករ យុទ្ធ សុខភិម (កំពង់ឆ្នាំង):** ចេះគិតច្រើន ចេះសរសេរ ចេះអាន ឧស្សាហ៍ ក្លាហាន ហ៊ាននិយាយ និងសម្របសម្រួលក្រុមបាន។ ពីមុនក្នុងភូមិគ្មានក្រុមសន្សំ បច្ចុប្បន្នបង្កើតបាន ៩ ក្រុម មាន ៨០ គ្រួសារចូលរួម មានប្រាក់សន្សំចំនួន ១៩ លានរៀល។

**កសិករ ង៉ែត ចាំវ (តាកែវ):** មុនសហការគឺដាំដំណាំលក់តែម្នាក់ឯងដោយមិនមានគំនិតផ្សព្វផ្សាយឱ្យអ្នកដទៃចេះ ក្រោយពីចូលសហការបានអនុវត្ត ប.វ.ស និងបានផ្សព្វផ្សាយដល់អ្នកភូមិ បង្កើតក្រុមស្ត្រីឱ្យមានភាពក្លាហាន ចេះសន្សំប្រាក់ ជួយគ្នាចូលរួមអភិវឌ្ឍន៍ធ្វើថ្នល់ ។ល។

**ចំណាប់អារម្មណ៍របស់សិស្សអភិវឌ្ឍន៍ជនបទ**

**ឡាយ ស្រីណុត (តាកែវ):** កើនឡើងនូវសមត្ថភាពក្នុងការគិត និយាយ ក្លាហាន សរសេរ បង្កើតក្រុមសន្សំក្នុងចំណោម YCL ២០ នាក់ មានទុន ៣ លានរៀល។ មានការសប្បាយរីករាយដោយបានស្គាល់ភូមិសាស្ត្រ និងតំបន់ច្រើននៅក្នុងខេត្តរបស់ខ្លួន។

**ចំណាប់អារម្មណ៍របស់ជំនួយការតាមមូលដ្ឋាន** (CFA)

**ស៊ុន ប៊ុនសេង** (CFA-ILFARM-TK)**:** ការអនុវត្តន៍ចាប់ផ្តើមពីខ្លួនឯង ដូចជាធ្វើ ប.វ.ស ចិញ្ចឹមសត្វ ក្រោយមកបានប្រលងចូលជាបុគ្គលិក សេដាក នៅក្នុងគម្រោង CSPPM ។

**សម ល្អប្រណិត:** (CFA-ILFARM-TK)**:** ពីមុនជា YCL នៅគម្រោង ILFARM-TK ក្រោយបញ្ចប់វគ្គមួយឆ្នាំ បានប្រឡងចូល CFA។ មុនចូលវគ្គបណ្តុះបណ្តាល គិតតែពីរៀន មិនមានគោលដៅ តែក្រោយពីបានសហការបានចេះពីបច្ចេកទេសកសិកម្ម និងការអភិវឌ្ឍន៍ជនបទ ហើយបានប្រឡងចូលជាបុគ្គលិក សេដាក នៅគម្រោង CSPPM ។ សំណូមពរឱ្យអង្គការសេដាក បន្តការបណ្តុះបណ្តាលដល់ YCL ដើម្បីជួយពង្រឹងសមត្ថភាពអ្នកនៅជនបទ។

**ពេលរសៀល: អ្នកសម្របសម្រួល លោក យឹម សុផាណ្ណា និងលោកប្រាក់សេរីវឌ្ឍន៍**

កិច្ចប្រជុំបានបន្តដោយការឡើងចំណាប់អារម្មណ៍របស់បុគ្គលិក សហគ្រាស និងវិទ្យាស្ថានក្រោយពីស្វ័យតភាព:

☞ ជាកិច្ចផ្តើមកម្មវិធី លោក អ៊ី ណារ៉ុន និយាយរឿងកំប្លែង ដោយដំណាលពីលោក អាល់បែរត៍

**លោក ប៊ុន ពេញភ័ក្ត្រ** (CESDE)**:** ពីមុនជាបុគ្គលិកគម្រោង JFPR (2003-2008) គឺមានតែផែនការចាយ។ នៅឆ្នាំ ២០០៨ ជាបុគ្គលិកនៅផ្នែកសហគ្រាសដើម្បីអភិវឌ្ឍន៍សង្គម ដែលសកម្មភាពសំខាន់ៗមានដូចជា កុងស៊ីកាប់មាន់ កាប់ជ្រូក ភោជនីយដ្ឋានបក្សីស្រុក ដែលមានផែនការចាយ និងផែនការរកចំណូល។ ការពិបាកចិត្តគឺការរកផលិតផលមកផ្គត់ផ្គង់ទីផ្សារ ដូចជាបន្លែ ឯការបើកភោជនីដ្ឋានលក់អត់ដាច់ ខាត បានដូរចរិតមកជាអ្នកបម្រើអតិថិជន។ ទោះជាយ៉ាងណាបានរៀនសូត្រចំណេះដឹងទាក់ទងនឹងជំនួញ ការក្តាប់ព័ត៌មានទីផ្សារ ការទទួលខុសត្រូវខ្ពស់ អតិថិជន មានស្បៀងអាហារសុវត្ថិភាព លក់បានថ្លៃ និងអតិថិជនមានការកើនឡើង។ មានការពិបាកចិត្តដោយតួលេខអវិជ្ជមាន តែយើងក៏បានដឹងពីមូលហេតុនៃចំណេញ-ខាត។

**អ្នកស្រី ឆេង ណារ៉ាត្រី** (CESDE)**:** ធ្វើការនៅផ្នែកជំនួញគឺលំបាកចិត្តច្រើន ពិសេសនៅពេលឃើញតួរលេខអវិជ្ជមាន ពេលទូទាត់ចុងខែ មិនតែប៉ុណ្ណោះបានរៀនសូត្រច្រើនថែមទៀតជុំវិញការងារជំនួញ។

**អ្នកស្រី តុង ចាន់ឆាង** (CILD)**:** ក្រោយពីបានបែកពី សេដាក ធំ ឃើញថាការទទួលខុសត្រូវមានការកើនឡើងខ្ពស់ទាំងអស់គ្នា ធ្វើផែនការ ទោះបីការងារយើងរៀនធ្វើទាំងអស់គ្នា និងជួយគ្នាម្នាក់បន្តិចៗ មានភាពជាម្ចាស់លើស្ថាប័ន ទុកស្ថាប័នជាកម្មសិទ្ធិរបស់ខ្លួន មានការសន្សំសំចៃ បើចង់បានប្រាក់ខែច្រើនត្រូវខំរកចំណូលឱ្យបានច្រើនដែរ។ គ្រប់ៗគ្នាចែករំលែកគ្នាក្នុងការគ្រប់គ្រង សង្ឃឹមថាទៅមុខរៀបចំឱ្យកាន់តែច្បាស់ថែមទៀត។

- ☞ បន្ទាប់មកទៀត **លោក ឡាង សេងហ៊ាង** បង្ហាញពីលទ្ធផលការងារឆ្នាំ ២០០៨ របស់ផ្នែក CESDE ដូចមាននៅក្នុង Slide។

☞ បន្ទាប់មកទៀត **លោក សម រិទ្ធ** បង្ហាញពីលទ្ធផលការងារឆ្នាំ ២០០៨ របស់ផ្នែក CILD ដូចមាននៅក្នុង Slide។ បន្ថែមលើការបង្ហាញ លោកបានចំណាប់អារម្មណ៍ផ្ទាល់ខ្លួនថា ពេលនៅជាមួយ សេដាក គឺអ្វីៗអាស្រ័យលើផ្នែកកណ្តាល តែដល់ពេលវិមជ្ឈការគឺមានការទទួលខុសត្រូវខ្ពស់ និងប្រជុំច្រើន ហើយបញ្ហាដែលប្រឈមគឺទាំងធនធាមនុស្ស និងហិរញ្ញវត្ថុ។

**សំរាកអាហារសម្រន់ (១៥ នាទី):**

- ☞ ពេលចូលមកវិញលោក ហ៊ួរ ស្រេង និយាយរឿងកំប្លែងដើម្បីដាស់អារម្មណ៍
- ☞ បន្ទាប់មក **លោក ស៊ឹម សាមឿន** បង្ហាញពីលទ្ធផលការងារឆ្នាំ ២០០៨ របស់ផ្នែក Field Program ដូចមាននៅក្នុង Slide។

☞ **លោក សេង សុភ័គ** បង្ហាញបន្ថែមពីគម្រោងទឹក ដោយលោកបញ្ជាក់ថា សហគមន៍អ្នកប្រើប្រាស់ទឹកស្ទឹងជីនិតធ្វើការផ្តោតសំខាន់ទៅលើ ៤ ចំណុចគឺៈការរៀបចំដំណើរការស្រោចស្រពទឹករដូវវស្សា និងរដូវប្រាំង, ការថែទាំប្រព័ន្ធធារាសាស្ត្រ, ការពង្រឹងបន្ថែមលើបទបញ្ជាផ្ទៃក្នុង និងការប្រមូលប្រាក់សេវាកម្មក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្រ។

☞ **លោក ប៉ាន សុភាព** បង្ហាញពីវេទិកាគ្រូបង្រៀន និងសំវាទដើម្បីអភិវឌ្ឍន៍ ដែលនៅឆ្នាំ ២០០៨ ធ្វើបានចំនួន ២៨ វេទិកា និងសំវាទដូចការគ្រោងទុក និងមានអ្នកចូលរួមប្រមាណ ១៧០០ នាក់។ ដោយឡែកលោកក៏បានឱ្យដឹងអំពីផែនការនៅឆ្នាំ ២០០៩ ដែលគ្រោងនឹងរៀបចំធ្វើចំនួន ៤០ លើកនៅទូទាំង ៩ ខេត្តក្រុង។

☞ **លោក គាម មករាឌី** បង្ហាញពីលទ្ធផលការងារឆ្នាំ ២០០៨ របស់ផ្នែកសេវាកម្មស្រាវជ្រាវ និងប្រឹក្សាយោបល់ ដូចមាននៅក្នុង Slide ក្នុងនោះលោកបានលើកឡើងថា នៅប្រទេសកម្ពុជាបច្ចុប្បន្ន យ៉ាងហោចណាស់ក៏មានថ្នាំពុលគីមីប្រមាណ ១៤៧ មុខកំពុងចរាចរប្រើប្រាស់។

☞ **អ្នកស្រី ស៊ិន អង្គារសោភ** បង្ហាញពីលទ្ធផលការងារឆ្នាំ ២០០៨ របស់ផ្នែកបោះពុម្ព និងទំនាក់ទំនងដូចមាននៅក្នុង Slide។

☞ បន្ទាប់មកលោក ប្រាក់ សេរីវឌ្ឍន៍ បានធ្វើការសំយោគរួមថា ជាទូទៅផ្នែក សេដាក-អភិវឌ្ឍន៍នៅឆ្នាំ ២០០៨ គឺល្អច្រើន និងអាចដំណើរការបាន។

☞ បន្ទាប់មក ជាការសរុបលទ្ធផលប្រចាំថ្ងៃ បុគ្គលិកមួយចំនួនបានឡើងចំណាប់អារម្មណ៍ៈ

**លោក ប៉ាន សុភាពៈ** ចំពោះលោក ការប្រជុំពេញមួយថ្ងៃ លោកមានការចាប់អារម្មណ៍ទៅលើការបែងចែករចនាសម្ព័ន្ធគ្រប់គ្រងរបស់ សេដាក ពីអភិវឌ្ឍន៍ទៅលក្ខណៈជំនួញឃើញថា បុគ្គលិកមានការទទួលខុសត្រូវខ្ពស់ សន្សំសំចៃ ចេះរកលុយ និងបម្លែបម្រួលជាវិជ្ជមានមួយចំនួនដូចជា CFA បុគ្គលិកថ្មី និងកសិករដែលឈានទៅរកអន្តរជាតិ ព្រមទាំងបានលើកឡើងអំពីអត្ថន័យការសន្សំ ដែលសំដៅទៅលើទាំងលុយ កេរ្តិ៍ឈ្មោះ និងសុខភាព។

**កញ្ញា សយ សុភ័ក្ត្រាៈ** ចាប់អារម្មណ៍ខ្លាំងចំពោះការដែលបានអញ្ជើញកសិករមកបង្ហាញ ព្រមទាំងការខិតខំប្រឹងប្រែងច្រើនជាងមុនរបស់បុគ្គលិកនៅក្រោយពេលចែកជាផ្នែក និងស្វ័យគ្រប់គ្រង។

**លោក អ៊ុង តារារ័ត្នមុន្នីៈ** ជាចំណាប់អារម្មណ៍របស់លោក ក្រោយការប្រជុំពេញមួយថ្ងៃ លោកបានលើកឡើងអំពីអត្តសញ្ញាណរបស់ សេដាក។ ទស្សនៈទានកសិកម្មជាចម្បង ពីមុនផ្តោតតែលើការរៀនសូត្រ តែឥឡូវឈានដល់ការបង្រៀន បណ្តុះបណ្តាល និងការស្រាវជ្រាវ។ ត្រូវបញ្ជ្រាបការគ្រប់គ្រងទៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។ ស្មារតីក្រុមខ្លាំង, ការប្តូរអាកប្បកិរិយា ដោយរៀនពីកំហុស, ការដឹកនាំដោយមានការចូលរួម។ ក្រៅពីនេះ លោកបន្តចាប់អារម្មណ៍ទៅលើកញ្ចប់ ៤ សំខាន់ៗគឺៈ

- បច្ចេកទេស (សង្គម និងសេដ្ឋកិច្ច)ៈ ពិសេសគឺ ប.រ.ស.។ សេដាក មិនត្រឹមតែធ្វើការទៅលើកសិកម្មប៉ុណ្ណោះទេ តែថែមទាំងពហុវិស័យ ដូចជា អប់រំ និងសុខាភិបាល ហើយមានទទួលយក និងសាយភាយ។ ពិសេសជាងនេះទៅទៀត សេដាក ចាត់ទុកដៃគូស្មើភាព ដូចជានៅក្នុងក្រុមប្រឹក្សាភិបាល សេដាក មានសមាសភាពកសិករជាដើម។ ជារួមអ្វីដែលខ្ញុំកំពុងគិត គឺ សេដាក កំពុងធ្វើ។

- ផ្នែកស្ថាប័នៈ សេដាក បានបន្សល់ទុកនូវរចនាសម្ព័នមួយដ៏សំខាន់ និងរឹងមាំ ទាំងផ្នែកសាធារណៈ និងឯកជន។ យើងផ្តល់ទៅដល់ថ្នាក់មូលដ្ឋានដែលរដ្ឋាភិបាលទៅមិនដល់ ដូចជាការចងក្រងក្រុម សមាគម សហគមន៍ និងសហព័ន្ធ និងការបញ្ចូលនូវវប្បធម៌ចែករំលែក។ ប្រព័ន្ធធ្វើការវិមជ្ឈការគឺសំខាន់ ការចងក្រងបណ្តាញ។ ជារួម គ្រប់វិស័យ ដើម្បីឈានដល់ការបំបាត់ភាពក្រីក្រ បន្ថែមនូវកំណើនសេដ្ឋកិច្ច។ វិមជ្ឈការ គឺសំដៅដល់ការផ្ទេរ ៣ ទៅថ្នាក់ក្រោមគឺ មុខងារ, មធ្យោបាយ និងតួនាទី។

- ហិរញ្ញវត្ថុៈ ការគ្រប់គ្រងហិរញ្ញវត្ថុគឺសំខាន់មែនទែន ហើយសំខាន់មួយទៀតគឺការងារសន្សំ ដែលបានឈានមកដល់កម្ចី Loan។

- ផ្នែកបរិស្ថានៈ វាជារឿងល្អ រក្សាដដែល តែត្រូវគិតបន្ថែមរឿងកំណើនសេដ្ឋកិច្ច។ ដោយឡែករឿងមួយចំនួនទៀត ដែលយើងគួរត្រូវសួរខ្លួនឯងផងដែរនោះគឺ :

១- ពេលដែលយើងឈានដល់សហគ្រាស តើយើងត្រូវធ្វើយ៉ាងណាត្រូវបញ្ជ្រាបការគ្រប់គ្រង នូវអត្តសញ្ញាណ ទៅនឹងខ្លឹមសាររកស៊ី?

២- នៅពេលគេស្គាល់ សេដាក ឥឡូវ ហើយឥឡូវ សេដាក រកស៊ី ចំពោះច្បាប់ តើគួរបញ្ចុះបញ្ចូលនរណាដែលអាចជួយយើងបាន?

៣- ដូចគ្នាដែរតើស្ថាប័នក្នុងជួររដ្ឋាភិបាលណាមួយដែលអាចជួយយើង និងអាចរកស៊ីជាមួយយើងបាន?

៤- យន្តការដើម្បីរក្សា ឬធានានូវអត្តសញ្ញាណរបស់យើងដើម្បីបញ្ជ្រាប និងរក្សានូវវប្បធម៌និយាយគ្នា ចងបណ្ដាញគ្នារវាងក្រុម និងក្រុម និយាយរួមធានាឱ្យគ្រួសារ សេដាក ប្រើភាសាតែមួយ?

៥- ការប្រើបច្ចេកវិទ្យា ICT ។

ចុងបញ្ចប់លោកបានបញ្ជាក់ថា ខ្ញុំស្រមៃដល់ចំណុចមួយគឺ តើសកម្មភាពទាំងប៉ុន្មានដែល សេដាក ធ្វើ យើងអាចសរសេរជាឯកសារបានដែរឬទេ? គឺសរសេរ និងបង្ហាញពីសេវាកម្មរបស់ សេដាក ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ខ័ណ្ឌ-ស្រុក។ មួយវិញទៀត លោកមានប្រសាសន៍ថាខ្ញុំរៀនបានពាក្យពីរម៉ាត់ពីអង្គប្រជុំគឺ អាចម៌គោ និង សេដ្ឋីស្រុកស្រែ។

**ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៨: (ពេលព្រឹក) អ្នកសម្របសម្រួល: អ្នកស្រី តុង ចាន់ធាង**

ជាកិច្ចចាប់ផ្ដើមលោក ឃឹម សុផាណ្ណា ចែករំលែករឿងកំប្លែង។ បន្ទាប់មកលោកចំណាប់អារម្មណ៍ចំពោះ ថ្ងៃទី ១ ដូចជា: ការរៀនសូត្រ ផ្សារភ្ជាប់នឹងការរីករាយ, ទាក់ទងនឹងកាតមួយដែលបុគ្គលិកសរសេរថា ហេតុអ្វីចាំបាច់វិមជ្ឈការ និងដាក់ក៏រិតខ្លួនឯង? ដោយលោកពន្យល់ថា ការមានបក្សពួកគឺជារឿងធម្មតា សំខាន់គឺកុំឱ្យបង្កើតបក្សដើម្បីផ្ដល់រំលំគ្នា។ មតិរិះគន់ យើងអាចយកមកគិតដើម្បីកែលំអ ឬអាចមិនខ្វល់។ ភាពរីកចំរើនមួយចំនួនទៀតដូចជាគេកាន់តែមានជំនឿ និងការថយចុះនូវការរើសអើងជាដើម ពិសេសលោកបានផ្ដាំដល់បុគ្គលិកត្រូវគិតពីសុខភាពខ្លួនផង។

☞ បន្ទាប់មកទៀត បណ្ឌិត យ៉ង សាំងកុមារ បង្ហាញពីយុទ្ធសាស្ត្រសម្រាប់ សេដាក ឆ្នាំ ២០០៩-២០១១ ប៉ុន្តែមុននឹងការបង្ហាញលោកចាប់អារម្មណ៍ទៅលើអ្វីដែលយើងកំពុងធ្វើ និងបានធ្វើកន្លងមកដូចជា:

១- បញ្ហាវិមជ្ឈការ (របៀបនៃការគ្រប់គ្រង) ចំពោះ សេដាក វាទាក់ទងទៅនឹងស្ទីលនៃការដឹកនាំ ដោយលោកបានលើកឡើងពីឧទាហរណ៍សង្គមកម្ពុជា និងសង្គមប្រទេសថៃ។

២- បញ្ហាបក្សពួក ឬក្រុម: ប្រសិនបើបក្សពួកក្រុមការងារគឺជារឿងធម្មតា (ស្វ័យភាពនៃការគ្រប់គ្រង) ប៉ុន្តែបក្សទី ២ គឺខ្សែ វាគ្រោះថ្នាក់។

៣-ឃ្លាមួយចំនួនដូចជា "អ្វីដែលគាត់ស្រមៃ គឺយើងកំពុងធ្វើ" របស់លោក អ៊ុង តារាវ័ត្តមុនី។ "អ្វីដែលខ្លួនគាត់អត់ហ៊ានយល់សប្តិគឺយើងហ៊ានធ្វើឱ្យក្លាយជាការពិត", "យើងប្រើពាក្យ Agricole តែយើងធ្វើអភិវឌ្ឍន៍ និងវិស័យច្រើនទៀត", "សេដាក គឺជាអង្គការមួយ Dynamic រៀនសូត្រជាប់ជានិច្ច ដែលយើងគួររៀនតាម" ។

៤- អ្វីដែលយើងកំពុងធ្វើអាចខុសច្បាប់ ឬមិនស្របច្បាប់ ព្រោះច្បាប់អត់ទាន់មាន តែយើងអាចចូលរួមធ្វើច្បាប់តាមក្រោយ ។

៥- រឿងសុខភាព "សេដាក គិតគូរពីបញ្ហាសុខភាព" ដូចកាតរបស់ដេវីត ហើយលោកបានពន្យល់អំពីទ្រឹស្តីអក្សរ "ហ" ដែលមានហូរចេញពីរប្រភេទ និងហូរចូលពីរប្រភេទ

☞ បន្ទាប់មកទៀត បណ្ឌិត យ៉ង សាំងកុមារ បន្តបង្ហាញពីយុទ្ធសាស្ត្រសម្រាប់ សេដាក ឆ្នាំ ២០០៩-២០១១ ដូចមានបង្ហាញក្នុងស្លាយ ។ បន្ទាប់មក បានចែកកាតដល់អ្នកចូលរួមដើម្បីសរសេរឆ្លើយទៅនឹងសំនួរដែលថា:

១- តើចង់ឃើញ សេដាក ទៅមុខទៀតឬទេ? ហេតុអ្វី?

២- នៅឆ្នាំ ២០១១ តើយើងចង់ឱ្យគេមើល ឬនិយាយពី សេដាក ថាយ៉ាងដូចម្តេច?

បន្ទាប់មក លោកបានអានកាតមួយរបស់បុគ្គលិកដែលសរសេរថា ចង់ឱ្យ សេដាក មានជានិរន្តរ៍ដើម្បីអភិវឌ្ឍន៍ទាំងស្មារតី និងបច្ចេកទេស ។ លោកថា សេដាក ធ្វើការគិតគូរទៅដល់ផ្នែកសេដ្ឋកិច្ច បរិស្ថាន សុខភាព និងនយោបាយ ។ បេសកម្មរបស់ សេដាក គឺធ្វើការពង្រឹងសមត្ថភាព ចងក្រងក្រុម សមាគម និងអង្គការកសិករដើម្បីចេះសហការជួយគ្នាទៅវិញទៅមក និងអាស្រ័យលើខ្លួនឯង ធ្វើឱ្យកសិករមានឱកាសទទួលបានព័ត៌មាន និងសេវាកម្ម ព្រមទាំងពង្រឹងនូវប្រជាធិបតេយ្យមូលដ្ឋាន ដើម្បីសំរេចបាននូវការអភិវឌ្ឍន៍ដោយមានការចូលរួម ។

☞ បន្ទាប់មកទៀត លោកបណ្ឌិតធ្វើការពន្យល់ពាក្យគន្លឹះមួយៗនៃគុណតម្លៃស្នូលរបស់ សេដាក ដែលមានដូចជា តម្លាភាព ការទទួខុសត្រូវ គោរពឱ្យតម្លៃគ្នា និងប្រជាធិបតេយ្យបែបចូលរួមជាដើម ។ លោកបណ្ឌិតក៏បានបង្ហាញពីការទទួលខុសត្រូវរបស់លោកសំខាន់ៗនៅក្នុងឆ្នាំ ២០០៩ នេះដែលផ្តោតសំខាន់លើការងារដឹកនាំ រួមមាន:

១- ចងក្រងក្រុមប្រធានអង្គការផ្សេងៗ រួមទាំងនាយកកម្មវិធី សេដាក

២- ធ្វើការជាមួយក្រុមអ្នកដឹកនាំ សេដាក ប្រមាណ ៣០ នាក់

៣- ក្រុមអ្នកដឹកនាំតាមជនបទ

៤- ការរៀបចំមូលនិធិសម្រាប់ការវិនិយោគ

ក្រៅពីការងារដឹកនាំ លោកបណ្ឌិតក៏នឹងបន្តការងារបេសកម្មសង្គម និងហិរញ្ញវត្ថុ ផងដែរ ក្នុងនោះលោកបណ្ឌិតបានលើកឡើងអំពីកូនរបស់ សេដាក ដែលមានដូចជា NEDC, FNN, CCC ។

**សំរាកអាហារសម្រន់ (១៥ នាទី):**

បន្ទាប់ពីការសំរាក កញ្ញា សយ សុភ័ក្រ្តា បន្តសម្របសម្រួលកម្មវិធីដោយលោក នៅ សារ៉ាត់ និយាយរឿងកំប្លែងដាស់អារម្មណ៍ ។

☞ បន្ទាប់មក លោក ស៊ឹម សាមឿន បង្ហាញពីយុទ្ធសាស្ត្រឆ្នាំ ២០០៩-២០១១ របស់ផ្នែក Field Program ដូចមាននៅក្នុងស្លាយ ។ នៅក្រោយការបង្ហាញលោកបណ្ឌិត យ៉ង សាំងកុមារ ឡើងធ្វើចំណាប់អារម្មណ៍អំពីក្រុមស្ត្រី ។

☞ បន្ទាប់មក លោក គាម មករាឌី បង្ហាញពីយុទ្ធសាស្ត្រឆ្នាំ ២០០៩-២០១១ របស់ផ្នែកសុខភាព និងបរិស្ថាន ដែលជាផ្នែកមួយថ្មី ដូចមាននៅក្នុងស្លាយ។ ក្រោយការបង្ហាញលោកបណ្ឌិត យ៉ង សាំងកុមារ ឡើងធ្វើចំណាប់អារម្មណ៍អំពីផ្នែកនេះដោយថាវាជាផ្នែកមួយសំខាន់ អាចធ្វើការសហការជាមួយក្រុមគោលដៅ ជាមជ្ឈមណ្ឌលសុខភាពនៅតាមមូលដ្ឋាន ហើយធនធានមនុស្សសម្រាប់ផ្នែកនេះអាចជាអ្នកជំនាញវេជ្ជសាស្ត្រ និងគីមី។

☞ បន្ទាប់មក អ្នកស្រី ពាន សុខា បង្ហាញពីយុទ្ធសាស្ត្រឆ្នាំ ២០០៩-២០១១ របស់ផ្នែក P&C ដូចមាននៅក្នុងស្លាយ។ បន្ទាប់ពីការបង្ហាញលោកបណ្ឌិត យ៉ង សាំងកុមារ ឡើងធ្វើចំណាប់អារម្មណ៍អំពីផ្នែកនេះដោយថា ផ្នែកនេះអាចដើរតួជាអ្នកផ្គត់ផ្គង់ផលិតផល និងសេវាកម្ម ហើយសំខាន់ត្រូវមានបុគ្គលិកផ្នែកទីផ្សារម្នាក់។

☞ បន្ទាប់មក លោក សម វិទូ បង្ហាញពីយុទ្ធសាស្ត្រឆ្នាំ ២០០៩-២០១១ របស់ផ្នែក CILD ដូចមាននៅក្នុងស្លាយ។ បន្ទាប់មក លោកបណ្ឌិត យ៉ង សាំងកុមារ បញ្ជាក់ថា សេដាក បានចំណាយលុយជិត ១០ ម៉ឺនលើការបណ្តុះបណ្តាលយុវជនជនបទ។ វិទ្យាស្ថានមានកន្លែងបណ្តុះបណ្តាលខ្លួនឯង ហើយវិទ្យាស្ថានអាចគិតពីការផ្តល់សញ្ញាប័ត្រដល់កសិករដែលបានចងក្រងសរសេរអំពីបទពិសោធន៍ និងជីវិតរបស់ខ្លួន។ លោកបណ្ឌិតបានផ្តាំផ្ញើថា យើងត្រូវចេះហាត់គិតដូចទៅនឹងរបៀបទីផ្សារ ថាតើនរណាជាអតិថិជនរបស់យើង ទើបងាយស្រួលកំណត់សេវាកម្មជូន។

**ពេលរសៀល: អ្នកសម្របសម្រួលលោក យឹម សុផាណ្ណា និងកញ្ញា លុយ ធារី**

ជាកិច្ចចាប់ផ្តើមកម្មវិធី បុគ្គលិកទាំងអស់ធ្វើការទស្សនាខ្សែវីដេអូស្តីពីសកម្មភាពការងារសង្ខេប សេដាក បន្ទាប់មក លោក ភន ភីរ៉ា, កញ្ញា គ្រួច សារ៉ន និងលោក យឹម សុផាណ្ណា និយាយរឿងកំប្លែងដើម្បីដាស់អារម្មណ៍

☞ បន្ទាប់មក លោក ឡាង សេងហ៊ង បង្ហាញពីយុទ្ធសាស្ត្រឆ្នាំ ២០០៩-២០១១ របស់ផ្នែក CESDE ដូចមាននៅក្នុងស្លាយ។ បន្ទាប់ពីការបង្ហាញលោកបណ្ឌិត យ៉ង សាំងកុមារ ធ្វើចំណាប់អារម្មណ៍ថា CESDE គឺជាការអភិវឌ្ឍន៍បែបជំនួញ ឧទាហរណ៍ករណីកសិករដាំបន្លែនៅកំពង់ឆ្នាំង។ ការបង្កើតផ្សារនៅតាមខេត្តអាចជាកំលាំងចលករមួយ ដើម្បីជំរុញការផលិត ប៉ុន្តែលោកបណ្ឌិតសង្កត់ធ្ងន់ថា ធ្វើយ៉ាងម៉េចពេលគំរោងចប់ ការងារនៅដដែល។

☞ បន្ទាប់មក លោក អ៊ូច ងាក់ បង្ហាញពីយុទ្ធសាស្ត្រឆ្នាំ ២០០៩-២០១១ របស់ផ្នែករដ្ឋបាល និងធនធានមនុស្ស ដូចមាននៅក្នុងស្លាយ។ ក្នុងនោះលោកបានពន្យល់សង្កត់ធ្ងន់អំពីកេសសុខភាព, កេសបណ្តុះបណ្តាល និងកេសប្រាក់បំណាច់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ផ្នែកកណ្តាល។ បន្ទាប់មក លោកបណ្ឌិត យ៉ង សាំងកុមារ ធ្វើចំណាប់អារម្មណ៍បន្ថែមទៅលើបីចំណុច:

១- ដូរសមាជិកក្រុមប្រឹក្សាភិបាល សេដាក ជាតំណាង FNN ចាស់ ដោយដាក់ប្រធាន FNN ថ្មីវិញគឺលោក អ៊ួន សុផល និងអ្នកស្រី ឃួន ស្រី។

២- ប្រកាសជ្រើសរើសនាយកប្រតិបត្តិ FNN។

៣- ការបង្ហាញរបស់ផ្នែក CCC អាចបង្ហាញដាច់ដោយឡែកនៅថ្ងៃណាមួយ។

☞ បន្ទាប់មក កញ្ញា លុយ ធារី បន្តសម្របសម្រួលកម្មវិធីវេទិកាទូទៅ ដែលផ្តល់ឱកាសដល់អ្នកចូលរួម និងបុគ្គលិកទាំងអស់បានសួរសំនួរ ឬលើកជាសំនួរ ។ ក្នុងនោះបុគ្គលិកមួយចំនួនបានសួរសំនួរមួយចំនួនដូចខាងក្រោម:

- លោក សុផា ផល: សួរអំពីភាពខុសគ្នានៃប្រាក់បំណាច់របស់បុគ្គលិកចប់កុងត្រា និងបុគ្គលិកដែលឈប់
- លោក ប៉ៅ វុទ្ធី: លើកឡើងថាមិនគួរខុសគ្នាទេព្រោះឈប់ដូចគ្នា
- លោក ប៊ុល ជីវីតា: បារម្ភអំពីភាពសហការគ្នា
- លោក គីន ម៉េងសែ: បារម្ភក្រែងផ្នែកមួយៗ ប្រឹងប្រែងមិនស្មើគ្នា
- លោក ជ្រួន ច្រាំង: ចាប់អារម្មណ៍ពីបញ្ហារបស់យុវជន
- លោក លួន សុខុម: លើកឡើងពីការងារសហការគ្នារវាង Field Program និង CESDEតើគួរធ្វើដោយរបៀបម៉េច? ។
- លោកបណ្ឌិត យ៉ង សាំងកុមារ: លើកឡើងអំពីបញ្ហា CESDE ដោយថាបើមិនបានជួយទេ សូមកុំបង្អាប់ឬបន្ទោស ។
- បុគ្គលិកថ្មីនៅខេត្តកំពត: លើកឡើងពីគុណភាពនៃផលិតផលសរីរាង្គ និងការសរសេរករណីសិក្សាអំពីកសិករនៅក្នុងទស្សនាវដ្តីកសិករ
- អ្នកស្រី ពាន សុខា: បំភ្លឺតបទៅនឹងការលើកឡើងរបស់បុគ្គលិកមកពីខេត្តកំពត
- លោក លឹម សុគុណដារុណ: លើកឡើងជុំវិញការផ្ទេរការគ្រប់គ្រងហាងបក្សីស្រុកទៅឱ្យឯកជន និងហេតុផលដែលមិនលើកមកធ្វើបទបង្ហាញដល់បុគ្គលិក ។

**សំរាកអាហារសម្រន់ (១៥ នាទី):**

☞ កម្មវិធីបន្ទាប់គឺការបោះឆ្នោតជ្រើសរើសបុគ្គលិកឆ្នើមប្រចាំឆ្នាំ និងបោះឆ្នោតជ្រើសរើសប្រុសស្អាត-ស្រីស្អាត ។ ជាលទ្ធផលចំពោះបុគ្គលិកឆ្នើមបីរូបគឺ លោក ឃិន ដារ៉ាវុធ ជាប់លេខ ១ កញ្ញា លុយ សុធារី ជាប់លេខ ២ និងកញ្ញា ចាន់ ស្រីញ៉ក់ ជាប់លេខ ៣ ។ រីឯពានរង្វាន់ប្រុសស្អាតបានទៅលើលោក ប៊ុន ពេញភ័ក្ត្រ និងស្រីស្អាតគឺកញ្ញា ខៀវ ចាន់ធូ ។

☞ បន្ទាប់មក លោក តាត់ សុខ ធ្វើការបូកសរុបលទ្ធផលរួមនៃកិច្ចប្រជុំរយៈពេលពីរថ្ងៃ ដែលរួមមានភាពរីកចំរើនជារួមសម្រាប់ការងាររបស់អង្គការសេដាក នៅក្នុងមួយឆ្នាំ ២០០៨ នេះរួមមាន:

- ក្រុមសន្សំប្រាក់
- ការផ្តល់ឱកាសការងារដល់យុវជន
- ការជម្រុញលើការងារអនុវត្តន៍បច្ចេកទេស ប.វ.ស. មានការកើនឡើង និងមានការចងក្រងក្រុមផលិតស្រូវសរីរាង្គ
- សកម្មភាពជំនួញសហគមន៍មានការរីកចំរើន
- វេទិកាគ្រូបង្រៀន

- ការប្រកាន់ខ្ជាប់នូវការស្រលាញ់ធម្មជាតិ និងសិរីរាង្គ
-ប្រព័ន្ធវិមជ្ឈការ និងស្វ័យតគ្រប់គ្រង ស្មារតីក្រុម
- ប្រព័ន្ធផ្សព្វផ្សាយមានការលេចធ្លោផងដែរ
ដោយឡែកការងារអភិវឌ្ឍន៍មូលដ្ឋាន:
- ឥរិយាបថការងារ វិន័យ និងការខិតខំប្រឹងប្រែងធ្វើការជាងមុន
- ចំណាប់អារម្មណ៏របស់កសិករ ការផ្លាស់ប្តូរមកភាពប្រសើរជាងមុនច្រើន
- បានស្តាប់ពីកម្មវិធីផ្សេងៗ ពិសេសសហគ្រាស សេដាក ការគ្រប់គ្រងហិរញ្ញវត្ថុ និងបុគ្គលិក
- ការបណ្តុះបណ្តាលយុវជនជនបទ
- មានកម្មវិធីច្រើននៅផ្នែកអភិវឌ្ឍន៏មូលដ្ឋាន
- ផ្នែកបោះពុម្ព និងទំនាក់ទំនងមានការប្រសើរជាងមុន
- បានស្តាប់ទស្សនៈវិស័យ និងគុណតំលៃ សេដាក
- យុទ្ធសាស្ត្រ សេដាក ឆ្នាំ ២០០៩-២០១១ ដែលចង់សំរេចបានភូមិគោលដៅចំនួន ៦០០០ ភូមិ ៥០ ម៉ឺនគ្រួសារកសិករ ដែលស្មើនឹងចំនួនប្រជាជន ២.៥ លាននាក់។
- បានស្វែងយល់បន្ថែមទៀតអំពីបញ្ហាថ្នាំពុលកសិកម្ម ក៏ដូចជាទាក់ទិននឹងសុខភាព
- ស្វែងយល់បន្ថែមពីកេសសុខភាព កេសបណ្តុះបណ្តាល និងគោលការណ៏រួមមួយចំនួនទៀត
☞ បន្ទាប់មក លោក គាត់ សុខ បានផ្តល់ឱកាសទៅដល់បុគ្គលិកដើម្បីឡើងចំណាប់អារម្មណ៏
- **លោក ហ៊ឹម សុភក្តិ:** បានយល់ដឹងច្រើនពីកម្មវិធីផ្សេងៗ ពិសេសគឺក្រុមសន្សំប្រាក់ដែលអាចជួយទ្រទ្រង់ដល់សហគ្រាស សេដាក។
- **លោក ផា សិលា:** កោតសរសើរចំពោះលោក ស អ៊ូច ដែលបងប្រាថ្នាធ្វើជាសេដ្ឋីស្រុកស្រែ។ ដោយឡែកសេដាក និងសហគ្រាស សេដាក ត្រូវពិចារណាចំពោះពាក្យរិះគន់មួយចំនួនដែលគេរិះគន់
- **លោក អ៊ួន សុផល:** បានយល់ដឹងច្បាស់ពីប្រវត្តិរបស់អង្គការសេដាក ឆ្លុះបញ្ចាំងពីការងារ និងពង្រឹងស្មារតីបន្ថែម ដើម្បីអនុវត្តការងារទៅថ្ងៃអនាគត។ សេដាក មានការលើកទឹកចិត្តខ្លាំងដល់បុគ្គលិកទាំងថវិកា សំភារ: និងស្មារតី។ លោកសំណូមពរសុំឱ្យបន្តសហការគ្នាកាន់តែខ្លាំងថែមទៀត ដើម្បីជាក្តីសង្ឃឹមដល់កសិករ។
- **លោក ឃឹម សុផាណ្ណា:** ការប្រជុំនេះមានការចូលរួមមិនបានទាំងអស់គ្នាទេ ដោយមានតែតំណាង តែមានការចូលរួមពីកសិករច្រើន ហើយសប្បាយចិត្តដោយបានឮចំណាប់អារម្មណ៏របស់កសិករ។ ភាពរីកចំរើនរបស់កម្មវិធីអភិវឌ្ឍន៏មួយចំនួនដូចជាចង្រ្កានឡូវថ្មី។ អ្វីដែលជាកត្តាសំខាន់របស់យើង គឺអ្វីដែលយើងកំពុងធ្វើ យើងសប្បាយចិត្តជាមួយវា ការទុកចិត្តគ្នា និងលើកទឹកចិត្តគ្នាទៅវិញទៅមក តែលោកសុំឱ្យបុគ្គលិក សេដាក អាចស្ម័គ្រចិត្ត

ទៅរត់តុនៅហាងបក្សីស្រុក។ នៅចុងបញ្ចប់លោកថា លោកមានការសប្បាយចិត្តបើទោះជាបានធ្វើការជាមួយគ្នាអស់រយៈពេល ១១ ឆ្នាំហើយក៏ដោយ។

- **បណ្ឌិត យ៉ង សាំងកុមារៈ** អ្វីដែលយើងទាំងអស់គ្នាចង់ឱ្យ សេដាក ទៅមុខទៀត គឺការគ្រប់គ្រងបែបវិមជ្ឈការគឺជារឿងសំខាន់ដែលទាមទារការសហការពីបុគ្គលិកទាំងអស់។ វាមានចំណុចសំខាន់ពីរ គឺទាក់ទងនឹងស្ទីលនៃការដឹកនាំ និងការផ្ទេរដែលសំដៅដល់ការអភិវឌ្ឍន៍អាស្រ័យលើខ្លួនឯង។ ចំពោះការប្រកួតប្រជែងរបស់ផ្នែកមួយៗគឺមានន័យពីរផងដែរ ដែលទី ១ សំដៅដល់ការផ្តល់រង្វាន់ និងទី ២ គឺដើម្បីភាពរីកចំរើន។ លោកបណ្ឌិតសម្តែងទឹកចិត្តសប្បាយ ដោយឃើញបុគ្គលិកភាគច្រើននៅចូលរួមប្រជុំចប់ចុងចប់ដើម។ លោកថាជារួមល្ខោនឆ្នាំ ២០០៨ បានលេងចប់ហើយ ឥឡូវត្រូវបន្តសំដែងសម្រាប់ឆ្នាំ ២០០៩ បន្តទៀត។ លោកប្រកាសបិទអង្គប្រជុំដោយការជូនពរទៅដល់បុគ្គលិកទាំងអស់។

បន្ទាប់មក បុគ្គលិកទាំងអស់បានអញ្ជើញពិសារអាហារសាមគ្គីរួមគ្នានៅការិយាល័យកណ្តាលអង្គការសេដាក។